## ឧបសម្ព័ន្ធទី ២. គុណភាព និង ប្រសិទ្ធភាព : តារាងសកម្មភាពគោលនយោបាយទូទាំងវិស័យឆ្នាំ ២០០៦-១០

| វិសាលភាពគោលនយោបាយ និង យុទ្ធសាស្ត្រ | សកម្មភាព (ត្រឹមដើមឆ្នាំ ២០០៦) | សកម្មភាព (ពាក់កណ្តាលឆ្នាំ ២០០៨) | សកម្មភាព(ត្រឹមដើមឆ្នាំ ២០១០) |
|---|---|---|---|
| បង្កើនប្រាក់លាភការ និងរង្វាន់លើកទឹកចិត្ត ដោយផ្សារភ្ជាប់ទៅនឹងការបំពេញការងារ តាមការឯកភាពលើផែនការកំណែទម្រង់បៀវត្ស/ប្រាក់ឧបត្ថម្ភរបស់គ្រូ ស្របទៅនឹងការបំពេញការងារ និងទំនួលខុសត្រូវ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ | - ផែនការដែលបានឯកភាពជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) ដើម្បីបង្កើនប្រាក់បៀវត្សរ៍/ប្រាក់ឧបត្ថម្ភផ្សេងៗដល់បុគ្គលិកបង្រៀន ដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលបានឯកភាពទាក់ទងនឹងការទទួលខុសត្រូវ និងការបំពេញការងារ ។ | - ក្រសួងអប់រំ យុវជន និងកីឡា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការពិនិត្យឡើងវិញរួមគ្នាលើប្រសិទ្ធភាពនៃការកែទម្រង់ប្រាក់បៀវត្សរ៍ និង សកម្មភាពពិនិត្យតាមដានដែលបានឯកភាពគ្នា ។ | - សិក្សាពីផលប៉ះពាល់នៃកំណែទម្រង់ប្រាក់បៀវត្សរ៍ដល់មន្ត្រីអប់រំ ទៅលើគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ។ |
| កែលំអគុណភាពបង្រៀន និងរៀន តាមរយៈការអនុវត្តសាលាកុមារមេត្រីទូទាំងប្រទេស និងកម្មវិធីត្រៀមចូលរៀនថ្នាក់ទី១ រួមមានការអប់រំបញ្ចូលគ្នា គោលវិធីសិស្សមជ្ឈមណ្ឌល បរិយាកាសសិក្សាឆ្លើយតបទៅនឹងយេនឌ័រ និងការចូលរួមពីគ្រួសារ និងសហគមន៍ និងប្រព័ន្ធគ្រប់គ្រងអប់រំប្រកបដោយប្រសិទ្ធភាព ។ | - គោលនយោបាយស្តីពីសាលាកុមារមេត្រី និងផែនការប្រតិបត្តិសាលាកុមារមេត្រី បានរៀបចំឡើង និងអនុម័ត ។ | - កម្មវិធីសាលាកុមារមេត្រី បានផ្តួចផ្តើមនៅគ្រប់ ២៤ ខេត្ត- ក្រុង ត្រឹមឆ្នាំសិក្សា ២០០៧-០៨ ។ | |
| បង្កើនគណនេយ្យភាព និងស្វ័យភាពប្រតិបត្តិការរបស់សាលារៀន និងគ្រឹះស្ថានបណ្តុះបណ្តាល ទាក់ទិនទៅនឹងថវិកាដំណើរការសាលារៀន និងគ្រឹះស្ថានសិក្សា និងការធ្វើសេចក្តីសំរេចចិត្ត ដោយការរៀបចំយន្តការធ្វើផែនការហិរញ្ញវត្ថុ និង ការទទួលខុសត្រូវសម្រាប់ថវិកាដំណើរការសាលាបឋមសិក្សា និងមធ្យមសិក្សា ដោយមានសេចក្តីណែនាំសម្រាប់ការចូលរួមលើការគ្រប់គ្រងរួមគ្នារវាងសាលារៀន មាតាបិតា និង សហគមន៍ និង | - កែលំអសេចក្តីណែនាំ និងអាំងឌីកាទ័របំពេញការងារស្តីពីការប្រើប្រាស់ថវិកាដំណើរការ រួមទាំងថវិកាផ្សេងៗ ។ | - ពិនិត្យឡើងវិញពីការរីកចំរើនផលប៉ះពាល់នៃការបង្កើនការបើកផ្តល់ថវិកាលើការបំពេញការងាររបស់សាលារៀន និង គ្រឹះស្ថានសិក្សា ។ | |

| | | | |
|---|---|---|---|
| ពង្រីកការអនុវត្តសវនកម្មផ្ទៃក្នុងចំពោះនាយកដ្ឋានមួយចំនួន ។ | | | |
| អនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មី រួមមានការអនុវត្តនៅបឋមសិក្សា និង មធ្យមសិក្សាបឋមភូមិនៃកម្មវិធីសិក្សាអប់រំមូលដ្ឋានថ្មី ដោយផ្តោតលើស្តង់ដាលទ្ធផលនៃការសិក្សានៅថ្នាក់ ទី ៣ ទី ៦ និងទី ៩ និងការចាប់ផ្តើមអនុវត្តកម្មវិធីបំណិនជីវិតមូលដ្ឋាន ។ | - អនុវត្តពេញលេញត្រឹមឆ្នាំ ២០០៧ ។ | | - ពិនិត្យឡើងវិញពីការវិវត្តនៃគោលនយោបាយកម្មវិធីសិក្សាថ្មីក្នុងឆ្នាំ ២០១០ ។ |
| កែលំអការបណ្តុះបណ្តាល និងវិក្រឹតការគ្រូ និងការចាប់ផ្តើមអនុវត្តប្រព័ន្ធវាយតម្លៃការបំពេញការងារបុគ្គលិកនៅគ្រប់កំរិតសិក្សារបស់ប្រព័ន្ធអប់រំ រួមមាន នីតិវិធីនៃការធ្វើរបាយការណ៍សមស្រប ។ | - ផែនការសកម្មភាពសម្រាប់ពង្រីកការធ្វើវិក្រឹតការ រួមមានការផ្តល់សិទ្ធិកាន់តែធំធេងដល់ខេត្ត-ក្រុង សម្រាប់ការធ្វើផែនការវិក្រឹតការ ។<br>- បញ្ចប់ការកែលំអយុទ្ធសាស្ត្រតំរូវការ/ផ្គត់ផ្គង់គ្រូបង្រៀន ដោយគិតទាំងការកែលំអតួនាទីរបស់សាលាគរុកោសល្យ និងវិធានការ ដើម្បីកែលំអបុគ្គលិកនៅសាលាគរុកោសល្យ និងប្រសិទ្ធភាពនៃសម្ភារូបវ័ន្ត ។ | - ការពិនិត្យឡើងវិញលើតំរូវការសាលាគរុកោសល្យបន្ថែមនៅក្នុងខេត្ត-ក្រុងដែលបច្ចុប្បន្នពុំទាន់មាន ។ | |
| ពង្រឹងគុណភាពនៃការបង្រៀន និង រៀន ដើម្បីធានាអោយគ្រូបឋមសិក្សា និង មធ្យមសិក្សាមានការយល់ដឹងពីគរុកោសល្យ និង ICT ។ | - បណ្តុះបណ្តាលគ្រូ ៥,០០០ នាក់ នៅគ្រប់កំរិតថ្នាក់ក្នុង ១ ឆ្នាំ ដោយរួមបញ្ចូល ICT ផងដែរ ។ | - ចាប់តាំងពីឆ្នាំ ២០០៦ គ្រូថ្មីត្រូវបានបណ្តុះបណ្តាលចំនួន ១០,០០០ នាក់ ដោយរួមបញ្ចូល ICT ផងនៅគ្រប់កំរិតថ្នាក់ ។ | - ចាប់តាំងពីឆ្នាំ ២០០៨ គ្រូថ្មីត្រូវបានបណ្តុះបណ្តាលចំនួន១០,០០០ នាក់ នៅគ្រប់កំរិតថ្នាក់ ។ |
| អនុវត្តស្តង់ដាអប្បបរមាលទ្ធផលនៃការសិក្សារបស់សិស្សថ្នាក់ទី ៣ ទី ៦ និងទី ៩ នៅទូទាំងប្រទេស ធានាថាមានការចែករំលែកការយល់ដឹងពីស្តង់ដាអប្បបរមា រវាងគ្រូ មាតាបិតា និង អ្នកពាក់ព័ន្ធផ្សេងៗទៀត និងតាមដានរបាយការណ៍លទ្ធផលតែសនៅគ្រប់សាលារៀនទូទាំងប្រទេស ។ | - ផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលតែសស្តង់ដាអប្បបរមា ចាប់ពីឆ្នាំ ២០០៥-០៦ ។ | - ផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលតែសស្តង់ដា ជារៀងរាល់ឆ្នាំ ។ | - ផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលតែសស្តង់ដា ជារៀងរាល់ឆ្នាំ ។ |

| | | | |
|---|---|---|---|
| បង្កើនតម្លាភាព និងកែលំអទំនួលខុសត្រូវ និងពិនិត្យតាមដានការបំពេញការងាររបស់គ្រូបង្រៀន សាលារៀន និងគ្រឹះស្ថានក្រោយមធ្យមសិក្សា ដោយផ្សព្វផ្សាយលទ្ធផលនៃការសិក្សារបស់សិស្សដល់សាធារណៈជន និងអាជ្ញាធរអប់រំនៅគ្រប់លំដាប់ថ្នាក់ តាមរយៈការកំណត់អោយបានច្បាស់លាស់នូវតួនាទី និងទំនួលខុសត្រូវនៃអធិការដ្ឋានអប់រំ និងនាយកដ្ឋានផ្សេងៗទៀតនៅថ្នាក់កណ្តាល ខេត្ត-ក្រុង និង អធិការអប់រំស្រុក-ខ័ណ្ឌ ។ តួនាទីក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន និង គ្រប់គ្រង ត្រូវបានជំរុញទឹកចិត្ត ។ | - ផែនការសកម្មភាពសម្រាប់ការផ្តើមកែលំអប្រព័ន្ធពិនិត្យតាមដានការបំពេញការងារដោយមានការណែនាំស្តីពីទំនួលខុសត្រូវរួម ។<br>- រៀបចំលក្ខណៈវិនិច្ឆ័យលំអិត សម្រាប់ការរៀបចំបង្កើតគ្រឹះស្ថានឧត្តមសិក្សា ។ | - ផ្សព្វផ្សាយជាសាធារណៈនូវស្តង់ដាឧត្តមសិក្សា នៅក្នុងគ្រឹះស្ថានសាធារណៈ និងឯកជន ។ | - រាយការណ៏ជូនរដ្ឋសភា ស្តីពីការរីកចំរើននៃការកែលំអស្តង់ដាអប់រំនៅគ្រប់កំរិតថ្នាក់ រួមទាំងតួនាទីរបស់ក្រសួងអប់រំ លើការធានាគុណភាពអប់រំ ។<br>- ពង្រឹងការអនុវត្តលក្ខណៈវិនិច្ឆ័យ និង គោលការណ៏ច្បាប់សម្រាប់ការរៀបចំបង្កើតគ្រឹះស្ថានឧត្តមសិក្សា និងការទទួលស្គាល់គុណភាពគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រឹមឆ្នាំ ២០១០ ។ |